## វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុ
## លេខ : 0000000១ អ.សក

***

| | | | |
|---|---|---|---|
| ខេត្ត | តាកែវ | លេខកូដ | ២១០៧០៤០១ |
| ស្រុក-ខ័ណ្ឌ | ស្រុកសំរោង | លេខក្បាលដី | ៣០ |
| ឃុំ - សង្កាត់ | ជំរះពេន | ទំហំ | ១៥៨៧ ម² |
| ភូមិ | ស្រែតាសុក | | |

ឈ្មោះកម្មសិទ្ធិករ **គីម គឿន** និងនាង **ឡុង មិន**
(ប្តី-ប្រពន្ធ)

**អាស័យដ្ឋាន** ភូមិស្រែតាសុក ឃុំជំរះពេន ស្រុកសំរោង ខេត្តតាកែវ
ប្រភពនៃការផ្តល់ដី រដ្ឋចែកអោយ
បន្ទុក គ្មាន







ធ្វើនៅភ្នំពេញ,ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០០០
**អគ្គនាយកសុរិយោដី និង ភូមិសាស្ត្រ**

មាត្រាដ្ឋាន ១/ ២០០០
យោងតាមអនុក្រឹត្យ ១១ អនក្រ.បក ចុះថ្ងៃទី ២២ ខែមីនា ឆ្នាំ ២០០០

> **ប្រការ** : បើលោកអ្នកបានទទួលវិញ្ញាប័ត្រសំគាល់ម្ចាស់អចលនវត្ថុនេះ ដោយបានចំណែកជាកេរ្តិ៍ ទទួលទិញ-ជួរក្តី ឬទទួលបញ្ចាំក្តីចូរលោកអ្នក កុំភ្លេចនាំម្ចាស់ដីទៅធ្វើលិខិតជាលាយលក្ខណ៍អក្សរនៅចំពោះមុខមន្ត្រីមានសមត្ថកិច្ច និងផ្លាស់ឈ្មោះនៅការិយាល័យ រៀបចំដែនដីនគរូបនីយកម្ម សំណង់ និងភូមិបាលស្រុកដែលដីធ្លីលោកអ្នកស្ថិតនៅ ព្រោះ បើកាលណាមិនបានបំពេញកិច្ចទាំង នេះទេ អចលនវត្ថុនោះនឹងទុកជាធានាប្រាក់លោកអ្នកក៏មិនកើត ឬទុកជាកម្មសិទ្ធិរបស់លោកអ្នកក៏ពុំបាន ។

***

## អនុក្រឹត្យ លេខ ១២ អនក្រ.បក
## ស្តីអំពីការបង្កើតរចនាសម្ព័ន្ធ នៃក្រុមប្រឹក្សារំសាយកងកំលាំងប្រដាប់អាវុធ

***

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៧២ ចុះថ្ងៃទី១៩ ខែមិនា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ

-បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ បក ចុះថ្ងៃទី១២ ខែ ឧសភា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតក្រុមប្រឹក្សារំសាយកងកំលាំងប្រដាប់អាវុធ

-បានឃើញអនុក្រឹត្យលេខ ៥២ អនក្រ បក ចុះថ្ងៃទី១២ ខែ ឧសភា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សារំសាយកងកំលាំងប្រដាប់អាវុធ

-យោងសេចក្តីជូនដំណឹងលេខ ២០៩ សជណ.គរ ចុះថ្ងៃទី០៩ ខែ កុម្ភៈ ឆ្នាំ ២០០០ ស្តីពីលទ្ធផលនៃសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នាថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០០០

-យោងតាមសំណូមពរភារកិច្ចចាំបាច់ និង តាមសំណើរបស់ប្រធានក្រុមប្រឹក្សារំសាយកងកំលាំងប្រដាប់អាវុធ

## សំរេច

## ជំពូក ១

## រចនាសម្ព័ន្ធ នៃក្រុមប្រឹក្សារំសាយកងកំលាំងប្រដាប់អាវុធ

**មាត្រា ១.-**

ត្រូវបានបង្កើតរចនាសម្ព័ន្ធ ០៤នាយកដ្ឋាន និង០១-មជ្ឈមណ្ឌលកុំព្យូទ័រ ចំណុះអោយអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សារំសាយកងកំលាំងប្រដាប់អាវុធ សំរាប់អនុវត្តកម្មវិធីរំសាយទ័ព រួមមាននាយកដ្ឋានដូចខាងក្រោម :

១-នាយកដ្ឋាន បុគ្គលិក និងរដ្ឋបាល

២-នាយកដ្ឋាន ប្រតិបត្តិការ និង ភស្តុភារ

៣-នាយកដ្ឋាន ហិរញ្ញវត្ថុ

៤-នាយកដ្ឋាន សមាហរណកម្ម

៥-មជ្ឈមណ្ឌលកុំព្យូទ័រ

## ជំពូក ២
## នាយកដ្ឋាន បុគ្គលិក និង រដ្ឋបាល

**មាត្រា ២ .-**

នាយកដ្ឋានបុគ្គលិក និងរដ្ឋបាល ធ្វើជាសេនាធិការអោយអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សា រំសាយកងកំលាំងប្រដាប់អាវុធ លើការងារ :

- គ្រប់គ្រងរដ្ឋបាល និងបុគ្គលិករបស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សារំសាយកងកំលាំងប្រដាប់អាវុធ ។
- រៀបចំលិខិតបទដ្ឋានសំរាប់ការគ្រប់គ្រងការងារ ក្នុងអគ្គលេខាធិការដ្ឋាន ។
- ធ្វើការវាយតំលៃតំរូវការ ការងារបណ្តុះបណ្តាលធនធានមនុស្សរបស់អគ្គលេខាធិការដ្ឋាន ។
- សំរបសំរួលការងារគ្រប់ផ្នែករបស់អគ្គលេខាធិការដ្ឋាន ជាមួយក្រសួង និង ស្ថាប័នពាក់ព័ន្ធ ចាប់ពីថ្នាក់លើរហូតដល់មូលដ្ឋាន ។
- គ្រប់គ្រង និងចរាចរឯកសាររដ្ឋបាលរបស់អគ្គលេខាធិការដ្ឋាន ដើម្បីធានាបានប្រសិទ្ធភាព និងសុវត្ថិភាពរដ្ឋបាល ។

## ជំពូក ៣
## នាយកដ្ឋាន ប្រតិបត្តិការ និងភស្តុភារ

**មាត្រា ៣ .-**

នាយកដ្ឋានប្រតិបត្តិការ និង ភស្តុភារ ធ្វើជាសេនាធិការអោយអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សារំសាយកងកំលាំងប្រដាប់អាវុធ លើការងារ :

- សហការជាមួយក្រសួងការពារជាតិ អគ្គមេបញ្ជាការដ្ឋាន គណៈកម្មការរំសាយទ័ពក្នុងកងយោធពលខេមរភូមិន្ទ ដើម្បីរៀបចំផែនការ ការកំណត់ចំនួនយោធិនដែលត្រូវរំសាយ ស្រង់បញ្ជីឈ្មោះទាហានរំសាយ និងធ្វើផែនការសំរាប់អនុវត្តការងាររំសាយជាក់ស្តែង តាមដំណាក់កាលនីមួយៗ ។
- សហការជាមួយគណៈកម្មការរំសាយទ័ពក្នុងកងយោធពលខេមរភូមិន្ទ ដើម្បីកំណត់ចំនួនមណ្ឌលប្រមូលផ្តុំសំរាប់រំសាយទ័ពតាមដំណាក់កាលនីមួយៗ និងរៀបចំផែនការដឹកជញ្ជូនយោធិនរំសាយពីមណ្ឌលប្រមូលផ្តុំទៅកាន់មូលដ្ឋាន ព្រមទាំងរៀបចំក្រុមការពារសុវត្ថិភាព សណ្តាប់ធ្នាប់ក្នុងមណ្ឌល និងជុំវិញមណ្ឌលប្រមូលផ្តុំតាមដំណាក់កាលនីមួយៗ ។
- សហការជាមួយគណៈកម្មការរំសាយទ័ព ជំនាញការបច្ចេកទេសចុះសិក្សាស្រាវជ្រាវអំពីជីវភាពរស់នៅរបស់យោធិនដែលត្រូវរំសាយ ដើម្បីរៀបចំកម្មវិធីជំនួយឧបត្ថម្ភជាក់ស្តែង ។
- លើកគំរោងផែនការតម្រូវការសំភារៈ សំរាប់អនុវត្តកម្មវិធីរំសាយទ័ព និងជំនួយឧបត្ថម្ភអតីតយុទ្ធជនកម្ពុជា ។
- រៀបចំបណ្តុះបណ្តាលសមាជិកក្រុមបច្ចេកទេសសំរាប់អនុវត្តកម្មវិធីរំសាយទ័ព ។

## ជំពូក ៤
## នាយកដ្ឋានហិរញ្ញវត្ថុ

**មាត្រា ៤ .-**

នាយកដ្ឋានហិរញ្ញវត្ថុ ធ្វើជាសេនាធិការអោយអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាវិសាលកងកំលាំងប្រដាប់អាវុធ លើការងារដូចខាងក្រោម :

- សហការជាមួយក្រុមជំនាញការបច្ចេកទេស និងគ្រប់នាយកដ្ឋានរបស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាវិសាលកងកំលាំងប្រដាប់អាវុធ ដើម្បីលើកគំរោងថវិកាសំរាប់រៀបចំអនុវត្តកម្មវិធីវិសាលយទ័ព ។
- លើកគំរោងតម្រូវការថវិកាចំណូល-ចំណាយរបស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាវិសាលកងកំលាំងប្រដាប់អាវុធ ដើម្បីអនុវត្តការងារតាមដំណាក់កាលនីមួយៗ ។
- ប្រមូលផ្តុំ និងធ្វើការសំរបសំរួលលើការស្នើសុំថវិកា ។
- ប្រមូលផ្តុំ និងសំរបសំរួលលើការចំណាយផ្សេងៗរបស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាវិសាលកងកំលាំងប្រដាប់អាវុធ ។
- គ្រប់គ្រងគណនីពិសេស និងគណនីបរិច្ចាគរបស់រាជរដ្ឋាភិបាល ក្នុងការអនុវត្តន៍កម្មវិធីជំនួយឧបត្ថម្ភ យោធិនវិសាលតាមដំណាក់កាលនីមួយៗ ។
- បូកសរុបរបាយការណ៍ចំណូល-ចំណាយដើម្បីរាយការណ៍ជូនអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាវិសាលកងកំលាំងប្រដាប់អាវុធ តាមការណែនាំជាក់ស្តែង ។
- រៀបចំ និងចុះបញ្ជីគណនេយ្យនូវរាល់ប្រតិបត្តិការចំណាយជាប្រចាំ ព្រមទាំងរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ស្តីពីការអនុវត្តន៍គំរោងតាមដំណាក់កាលនីមួយៗ ។

## ជំពូក ៥
## នាយកដ្ឋានសមាហរណកម្ម

**មាត្រា ៥ .-**

នាយកដ្ឋានសមាហរណកម្មធ្វើជាសេនាធិការអោយអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាវិសាលកងកំលាំងប្រដាប់អាវុធ លើការងារដូចខាងក្រោម :

- សហការជាមួយគណៈកម្មការវិសាលយទ័ពក្នុងកងយោធពលខេមរភូមិន្ទ រៀបចំចងក្រងឯកសារសំរាប់ធ្វើការអប់រំ និងធ្វើការផ្សព្វផ្សាយដល់យោធិនវិសាលក្នុងមណ្ឌលប្រមូលផ្តុំ ។
- បូកសរុបចំនួនយោធិនវិសាល និងចំនួនទាហានវិសាលតាមមណ្ឌល ដែលទៅរស់នៅតាមមូលដ្ឋាននីមួយៗ ។
- សហការជាមួយគណៈកម្មការអតីតយុទ្ធជនខេត្ត គណៈកម្មការអភិវឌ្ឍន៍ខេត្ត អង្គការអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាល ដើម្បីរៀបចំការអភិវឌ្ឍន៍ក្នុងសហគមន៍ ដែលអតីតយុទ្ធជនទៅរស់នៅ ។

- បូកសរុបលទ្ធផលការងារដែលបានអនុវត្ត ដើម្បីរាយការណ៍ជូនអគ្គលេខាធិការដ្ឋាន ។

## ជំពូក ៦

## មជ្ឈមណ្ឌល កុំព្យូទ័រ

៦ .-

មជ្ឈមណ្ឌលកុំព្យូទ័រ ធ្វើជាសេនាធិការអោយអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សារំសាយកងកំលាំងប្រដាប់អាវុធ លើការងារដូចខាងក្រោម :

រៀបចំប្រព័ន្ធកុំព្យូទ័រ និងគ្រប់គ្រងកម្មវិធីកុំព្យូទ័រ សំរាប់បញ្ចូលប្រវត្តិរូបយោធិន ។

បង្កើតតារាងបើកបៀវត្សរ៍របស់កងយោធពលខេមរភូមិន្ទតាមប្រព័ន្ធកុំព្យូទ័រ និងវិភាគទិន្នន័យដែល បានបញ្ចូលក្នុងប្រព័ន្ធកុំព្យូទ័រ សំរាប់បំរើអោយការងាររំសាយទ័ព ។

- ធានាសុវត្ថិភាពប្រព័ន្ធបច្ចេកទេស និងទិន្នន័យដែលបានបញ្ចូលក្នុងប្រព័ន្ធកុំព្យូទ័រ ។
- រៀបចំកម្មវិធីជាប្រចាំ ដើម្បីបណ្តុះបណ្តាលបុគ្គលិកកុំព្យូទ័រអោយមានសមត្ថភាពគ្រប់គ្រាន់សំរាប់បំរើអោយការងាររំសាយទ័ព ។

## ជំពូក ៧

## អវសានប្បញ្ញត្តិ

មាត្រា ៧ .-

បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៨ .-

អនុក្រឹត្យនេះមានតំលៃជាគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

មាត្រា ៩ .-

ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ក្រុមប្រឹក្សារំសាយកងកំលាំងប្រដាប់អាវុធ គណៈកម្មការរំសាយទ័ពក្នុងកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ។

រាជធានីភ្នំពេញ,ថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

***


ក្រុមប្រឹក្សារំសាយកងកំលាំងប្រដាប់អាវុធ
អគ្គលេខាធិការ
នាយកដ្ឋានហិរញ្ញវត្ថុ
អគ្គលេខាធិការរង
អគ្គលេខាធិការរង
អគ្គលេខាធិការរង
នាយកដ្ឋាន រដ្ឋបាល និងបុគ្គលិក
នាយកដ្ឋានប្រតិបត្តិការ និងគស្តុគារ
នាយកដ្ឋាន សមាហរណកម្ម
មជ្ឈមណ្ឌល កុំព្យូទ័រ